**មិនទុកនរណាម្នាក់ចោល**

- សង្គមទាំងអស់ រាប់ទាំងបុគ្គលទាំងឡាយដែលបាត់បង់ឱកាស និងជួបការលំបាកក្នុងការទទួលបានព័ត៌មាន និងសេវាសាធារណៈ ដោយសារហេតុផលផ្សេងៗ ដែលហេតុផលមួយចំនួនក្នុងនោះ ឆ្លុះបញ្ចាំងពីការរើសអើងដែលចាក់ឫសយ៉ាងជ្រៅ ការផាត់ចេញ វិសមភាព ឬការបែងចែកខាងនយោបាយ។ ព័ត៌មាន និងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ចាំបាច់ត្រូវយកចិត្តទុកដាក់ជាពិសេស ក្នុងការកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយ ដែលអាចប្រឈមនឹងហានិភ័យនៃការខកខាន ឬការផាត់ចេញ ដូចជា ជនជាតិភាគតិចខាងសាសនា ជាតិ ជាតិពន្ធុ ជនជាតិដើមភាគតិច ទេសន្តរប្រវេសន៍ ជនចំណាកស្រុក និងជនភៀសខ្លួន មនុស្សចាស់ជរា ជាដើម ជនដែលមានពិការភាព ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា (LGBTI) កុមារ ឬបុគ្គលដែលរងផលប៉ះពាល់ដោយសារភាពក្រីក្រខ្លាំង។

ស្ថាប័នសិទ្ធិមនុស្សជាតិ សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន អាចជួយកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយដែលអាចខកខាន ឬត្រូវបានគេផាត់ចេញ គាំទ្រលំហូរព័ត៌មានដែលអាចរកបានទៅដល់ក្រុមទាំងនេះ និងផ្តល់មតិត្រឡប់ដល់អាជ្ញាធរអំពីផលប៉ះពាល់នៃវិធានការទៅលើសហគមន៍ផ្សេងៗ។